

# នីឡា គ្រូពេទ្យតូច


Rizky Ramda

Ella Elviana



Let's Read

The Asia Foundation



នេះគឺជានាងតូចនីឡា។ ទោះបីជា នីឡាគឺជាក្មេងស្រីតូចម្នាក់ក៏ដោយ តែនាងមានថាមពលពិសេសមួយ គឺនាងអាចព្យាបាលសត្វដែលឈឺឱ្យជាឡើងវិញបាន។
ពេលនេះ អ្នកជំងឺរបស់នាងគឺជាសត្វខ្លាឃ្មុំដ៏គួរឱ្យស្រឡាញ់មួយក្បាល។



នីឡា សប្បាយចិត្តណាស់ នៅពេលដែលនាងអាចជួយសត្វខ្លាឃ្មុំបាន។ ឥឡូវនេះវាអាចដើរបានវិញហើយ។

នាងនិយាយលាវា ដោយផ្តាំវាថា «កុំភ្លេចផឹកថ្នាំផងណា៎!»



អូទេ! តើមានអ្វីកើតឡើងចំពោះស្បែករបស់នីឡា?
នាងត្រូវធ្វើថ្នាំពិសេសម៉្យាងដើម្បីព្យាបាលស្បែករបស់នាង។



ប៉ុន្តែគ្មានសល់ស្លឹកឈើសម្រាប់ធ្វើថ្នាំទៀតទេ។ ស្លឹកឈើ
ទាំងនោះ ត្រូវចូលទៅក្នុងព្រៃជ្រៅទើបអាចរកបាន។



ហេតុនេះ នីឡាក៏ចេញទៅរកថ្នាំ!



គ្មានអ្វីអាចបញ្ឈប់នាងបានទេ។



ទីបំផុត នាងក៏រកឃើញស្លឹកថ្នាំទាំងនោះ!

នីឡា បេះវាដាក់ក្នុងថង់ក្រណាត់របស់នាង។



ពេលនេះ នាងបេះរួចរាល់ហើយ អាចទៅផ្ទះដើម្បីធ្វើថ្នាំសម្រាប់ព្យាបាលស្បែករបស់នាង។
ប៉ុន្តែ.....
«អេ៎! តើឯងកើតអីមែនទេ សត្វស្វា? ហេតុអ្វីបានជាឯងអេះខ្លួនមិនឈប់អ៊ីចឹង?



អុំ! តាមពិតវាមានរបួសទេតើ!
នីឡា បានយកស្លឹកថ្នាំរបស់នាងទៅព្យាបាលសត្វស្វា។



នីឡា បានប្រាប់ទៅកាន់សត្វស្វាថា«ឯងកុំអេះវាទៀត ដឹងទេ?»



អស្ចារ្យមែន! បក្សីអេកូសនោះស្អាតណាស់!
ប៉ុន្តែ ហេតុអ្វីបានជាវាឈរស្ងៀមអ៊ីចឹង?



អ៊ូ! តាមពិត វាឈឺជើង។

ជាថ្មីម្តងទៀត នីឡា បានប្រើស្លឹកថ្នាំរបស់នាងដើម្បីព្យាបាល ជើងរបស់សត្វបក្សីនោះ។ នាងបានបិទស្លឹកថ្នាំនៅលើជើងរបស់ វា។



នីឡា និយាយទៅកាន់បក្សីថា «ខ្ញុំទៅសិនហើយ ឯងសម្រាក ចុះ បន្តិចទៀតជើងរបស់ឯងនឹងជាសះស្បើយ។»



អុំ! កូនឈ្លូសនេះក៏ត្រូវការជំនួយដែរ។ វាជាប់អន្ទាក់វល្លិ៍ហើយ។ នីឡា ប្រាប់វាថា «នៅឱ្យស្ងៀម! បន្តិចទៀតឯងនឹងមាន សេរីភាពហើយ!»



ជួយកូនឈ្លូសរួច នីឡាគិត«ខ្ញុំគួរតែកាត់វល្លិ៍នេះចោល ដើម្បីកុំឱ្យពួកវាទាក់សត្វផ្សេងៗទៀត»
ស្រាប់តែពេលនោះ...



...អ៊ុំ! មើលចុះ កូនឈ្លូសមើលទៅឃ្លានហើយ វាស៊ីស្លឹកថ្នាំ
របស់នីឡា។ នីឡា ក៏បណ្ដោយឱ្យកូនឈ្លូសស៊ីស្លឹកទាំងនោះ។
ប៉ុន្តែ នាងក៏ត្រូវត្រឡប់ទៅបេះស្លឹកនោះថែមទៀតដែរ។



ស្វាឃើញនាងដើរចូលទៅក្នុងព្រៃជ្រៅវិញ វាក៏សួរ៖
«ហេតុអ្វីបានជាឯងត្រឡប់មកវិញ?»
 នីឡាឆ្លើយថា «ខ្ញុំត្រូវការស្លឹកថ្នាំបន្ថែមដើម្បីព្យាបាលស្បែករបស់ខ្ញុំ។»



បក្សីអេកូសសួរនីឡាថា «តើឯងឈឺអី? ខ្ញុំមើលទៅស្បែករបស់ឯងគ្មានកើតអីទេ»

នីឡា មើលទៅដៃរបស់នាង ហើយនិយាយ«ហ៊ឹម ឯងនិយាយត្រូវហើយ»

នីឡា លែងមានកន្ទួលក្រហមនៅលើស្បែករបស់នាងទៀតហើយ។



ស្វានិយាយថា «មែនហើយ! ប្រហែលវាជាសះស្បើយ
ដោយសារតែឯងបានជួយពួកយើង»
នីឡា សើចហើយនិយាយថា«...ប្រហែលជាខ្ញុំគ្រាន់តែត្រូវការ
ខ្យល់បរិសុទ្ធនៅខាងក្រៅ ហើយនិងការហាត់ប្រាណខ្លះ»



ប៉ុន្តែនីឡានៅតែត្រូវការស្លឹកឈើដើម្បីធ្វើថ្នាំទុកនៅពេលក្រោយទៀត។

ស្វាក៏និយាយឡើងមកថា«ឯងបានជួយពួកយើង។ ពេលនេះ ខ្ញុំនឹងទៅជាមួយឯង ហើយជួយបេះស្លឹកថ្នាំជាមួយគ្នា»

ហើយពួកគេទាំងពីរក៏ដើរចូលទៅក្នុងព្រៃជ្រៅ។

អង្គការមូលនិធិអាស៊ី ២០១៩

សៀវភៅនេះត្រូវបានបង្កើតឡើងតាមរយ:សិក្ខាសាលាមួយ សម្រាប់ការបង្កើតសៀវភៅជាច្រើនទៅតាមភាសាក្នុងតំបន់ ដែលត្រូវបង្កើតឡើងក្នុងកិច្ចសហប្រតិបត្តិការរវាងមូលនិធិលីថារ៉ា អង្គការមូលនិធិអាស៊ីនិង ISI Padang Panjang នៅភាគខាងលិច សូម៉ាត្រា។ សិក្ខាសាលា និង ការអភិវឌ្ឍជំនាញ រួមទាំងការកែសម្រួល និងការរចនា សៀវភៅនេះ ត្រូវបានធ្វើឡើងដោយអង្គការ មូលនិធិ លីថារ៉ា។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Nilam Si Tabib (Nilam the Little Healer)*, Author: Rizky Ramda. Illustrator: Ella Elviana. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/